ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ: ១១១/២៥ ក.ប/ប្រ.ក.អ.ដ.ក

# ប្រកាស
# ស្តីពី
# សៀវភៅបើកប្រាក់

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីជូនដំណឹងលេខ ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

**ប្រការ១ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារត្រូវមាននិងប្រើប្រាស់ជាដរាបនូវសៀវភៅបើកប្រាក់ ដែលអាចមានទម្រង់ជាបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ ដូចមានគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ:(០២៣)៨៨២៧៦៩

**ប្រការ២ .-**

សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រត្រូវមានភ្ជាប់នូវកូដឆ្លើយតបរហ័ស (QR Code) ដែលទាញចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh ដើម្បីទទួលបានការបញ្ជាក់នូវភាពត្រឹមត្រូវតាមច្បាប់។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីបើកប្រាក់ឈ្នួល ក្នុងករណីមានការផ្លាស់ប្តូរ ឬបន្ថែមចំណុចព័ត៌មានក្នុងទម្រង់ផ្សេងពីគំរូដូចកំណត់ក្នុងប្រការ១ នៃប្រកាសនេះ ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

**ប្រការ៣ .-**

ដើម្បីប្រើប្រាស់សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រឱ្យបានត្រឹមត្រូវ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវបំពេញបែបបទនិងលក្ខខណ្ឌ ដូចខាងក្រោម៖

- ជ្រើសរើសរវាងការប្រើប្រាស់សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ
- ជ្រើសរើស និង/ឬបំពេញព័ត៌មានបើកប្រាក់ឈ្នួលបន្ថែមស្របតាមសកម្មភាពអាជីវកម្មរបស់សហគ្រាស គ្រឹះស្ថាន ក្នុងករណីជ្រើសរើសបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ
- ទាញយកសៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ ដើម្បីចុះហត្ថលេខានិងវាយត្រារបស់សហគ្រាស គ្រឹះស្ថាន បន្ទាប់មកត្រូវស្កេនបញ្ចូលទៅក្នុងប្រព័ន្ធវិញ ដើម្បីដាក់បញ្ចូលកូដឆ្លើយតបរហ័ស
- បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងបញ្ជីបើកប្រាក់ឈ្នួលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែបន្ទាប់។

**ប្រការ៤ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវរក្សាទុកឯកសារពាក់ព័ន្ធនឹងការប្រើប្រាស់សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រនៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ។ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវ៖

- រក្សាទុកសៀវភៅបើកប្រាក់នៅពេលបញ្ចប់ការប្រើប្រាស់សៀវភៅនោះ ក្នុងរយៈពេល ៣ (បី) ឆ្នាំ ឬ
- រក្សាទុកបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ ដែលបានបើកជារៀងរាល់ខែ ក្នុងរយៈពេល ៣ (បី) ឆ្នាំ។

អធិការការងារអាចត្រួតពិនិត្យសៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ និងឯកសារពាក់ព័ន្ធនៅគ្រប់ពេលវេលា។

**ប្រការ៥ .-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៦ .-**

ប្រកាសលេខ ២៦៩ សកបយ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការបង្កើតសៀវភៅបើកប្រាក់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ:...១១១/២៥ សហវ/ប្រក.អគក...ចុះថ្ងៃទី...៦...... ខែ សីហា...... ឆ្នាំ២០២៥ ស្តីពី
សៀវភៅបើកប្រាក់

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបើកប្រាក់

ថ្ងៃ.......................ខែ.............ឆ្នាំ.............ស័ក ព.ស.........
.......................ថ្ងៃទី............ខែ...........ឆ្នាំ..............

សៀវភៅទី.......

# សៀវភៅបើកប្រាក់

នាមករណ៍សហគ្រាស ៖ ...................................

សកម្មភាពអាជីវកម្ម ៖ ...................................

អាសយដ្ឋាន ៖ ផ្ទះលេខ......ផ្លូវ.......ភូមិ..........

ក្រុម.........ឃុំ/សង្កាត់............

ក្រុង/ស្រុក/ខណ្ឌ....................

រាជធានី/ខេត្ត.........................

QR Code

**នាមករណ៍សហគ្រាសៈ..............................................................**

**បញ្ជីបើកប្រាក់ឈ្នួលប្រចាំខែ........................ ឆ្នាំ.....................**

| ល.រ | គោត្តនាម និងនាម | សញ្ជាតិ | ថ្ងៃខែចូលបម្រើការងារ | មុខងារ | ប្រាក់ឈ្នួលសុទ្ធសាធ | ប្រាក់មុខងារ | ចំនួនថ្ងៃធ្វើការធម្មតា | ប្រាក់តាមចំនួនថ្ងៃធ្វើការធម្មតា | ចំនួនម៉ោងធ្វើការបន្ថែមម៉ោង | ប្រាក់ធ្វើការបន្ថែមម៉ោង | ចំនួនម៉ោងធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ | ប្រាក់ធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ | ចំនួនម៉ោងធ្វើការថ្ងៃបុណ្យ | ប្រាក់ធ្វើការថ្ងៃបុណ្យ | ប្រាក់រង្វាន់ផ្សេងៗ | ចំនួនប្រាក់ទាំងអស់ដែលត្រូវបាន | ប្រាក់ហូតទុក ពន្ធ និងវិភាជន៍ | | ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ | ប្រាក់បំណាច់អតីតភាពការងារ | | ប្រាក់អត្ថប្រយោជន៍ដែលមិនរាប់បញ្ចូលជាមួយប្រាក់ឈ្នួល | ចំនួនប្រាក់ដែលត្រូវបើក | ហត្ថលេខា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | សន្តិសុខសង្គម | ពន្ធ | | រំលឹកឆ្នាំចាស់ | ទូទាត់ក្នុងឆ្នាំ | | | |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |

ថ្ងៃ............. ខែ................ ឆ្នាំ.............
គណនេយ្យករ

ថ្ងៃ............. ខែ................ ឆ្នាំ.............
ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន

QR Code

